**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិចំនួន ០២កន្លែង សម្រាប់ផ្តល់ជូនក្រុមហ៊ុនធ្វើការវិនិយោគ រួមមាន៖

១. កំណត់តំបន់គ្រប់គ្រង ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីចំនួន **៧.៧៥០ ហិកតា (ប្រាំមួយពាន់ ប្រាំពីររយ ហាសិបហិកតា)** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ទីមរីង រ៉ាប់ប៊ើរ ខូអិលធីឌី**(TOMRING RUBBER CO., LTD) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៦៦២ សជណ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ជាឧបសម្ព័ន្ធ។

២. កំណត់តំបន់គ្រប់គ្រង ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីចំនួន **៧.៧០០** **(ប្រាំមួយពាន់ ប្រាំពីររយ)**ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តឧត្ដរមានជ័យ សម្រាប់ផ្ដល់ជូនក្រុមហ៊ុន **ដាតា រ៉ាប់ប៊ើរ (ខេមបូឌា) ខូអិលធីឌី** (DATA RUBBER (CAMBODIA) CO., LTD) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៦៦២ សជណ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្ដរមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០១១

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទី ទីតាំងដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន ដាតា រ៉ាប់ប៊ើរ (ខេមបូឌា) DATA RUBBER (CAMBODIA) Co., LTD

ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ លើផ្ទៃដី ៧៧០០ ហិកតា







| id | N | X | Y |
|---|---|---|---|
| 1 | A | 402352 | 1556402 |
| 2 | B | 400230 | 1558492 |
| 3 | C | 401696 | 1558789 |
| 4 | D | 401712 | 1559741 |
| 5 | E | 400067 | 1559676 |
| 6 | F | 399179 | 1559084 |
| 7 | G | 397116 | 1563505 |
| 8 | H | 401164 | 1564722 |
| 9 | I | 403786 | 1564525 |
| 10 | J | 404448 | 1561477 |
| 11 | K | 403749 | 1555391 |
| 12 | L | 405435 | 1561283 |
| 13 | M | 404876 | 1564570 |
| 14 | N | 407737 | 1564928 |
| 15 | O | 405061 | 1569647 |
| 16 | P | 407400 | 1572070 |
| 17 | Q | 408672 | 1571661 |
| 18 | R | 408675 | 1568410 |
| 19 | S | 408680 | 1562562 |
| 20 | T | 406562 | 1559992 |
| 21 | U | 405994 | 1555329 |

សញ្ញាសំគាល់

ទីតាំងដីវិនិយោគ

ផ្លូវជាតិ

ផ្លូវលំ

ស្ទឹង, អូរ

ផែនទី និងទិន្នន័យនេះ ជាឯកសារ

ភ្ជាប់នឹងលិខិតលេខ ...

ផែនទី និងទិន្នន័យនេះ ជាឯកសារ

ភ្ជាប់នឹងលិខិតលេខ ...

ចុះថ្ងៃទី ... ខែមិថុនា ... ឆ្នាំ ២០១១